# រឿង

# ព្រះនាង យសោធរា ពិម្ពា

## ពាក្យកាព្យ



ធម្មយាន ជាយានមត៌កកេរ
ចារជាប់បិតស្មេរ មិនរសាយ
ជាយាននាំមនុស្ស ឆ្លងអបាយ
ឈានរកត្រើយនាយ សួគ៌និព្វាន ។

ទទួលបានពីលោក ចៅ ឃុនសំរ៉េង ដល់ក្រុណាខ្មែរ
ដើម្បីដាក់ចូលក្នុង elibrary of Cambodia.

កញ្ញា 2015.

# រឿង
# ព្រះនាងយសោធរា ពិម្ពា

រៀបរៀងនិង និពន្ធ ដោយ
ឧបាសិកា **លី ឡាវុន**
(សមាជិក សមាគមអ្នកនិពន្ធខ្មែរ)

ពិនិត្យសាច់រឿងដោយ
អ្នកគ្រូធម្មចារ្យាសុធម្មា **ម៉ម សុខហេង**

សំរួលអក្ខរាវិរុទ្ធភាសាបាលី ដោយ
-ព្រះភិក្ខុ បិតប្បញ្ញោ **គង់ សុភាព**
-ព្រះភិក្ខុ **សីលវណ្ណោ រី ពុំ**
-លោកគ្រូធម្មាចារ្យ **ហ៊ី សារី**

**សំរួលអក្ខរាវិរុទ្ធភាសាខ្មែរ ដោយ**
អ្នកនាង **ហ៊ីរ តួចគន់**

**ព.ស.២៥៥៥ គ.ស.២០១២**

០១២ - ៦៤៧ - ៦៤៤

*រក្សាសិទ្ធិគ្រប់យ៉ាង*

# អារម្ភកថា

អក្សរសាស្ត្រ ជាផ្នែកមួយនៃអត្តសញ្ញាណជាតិហើយក៏ជាព្រលឹងមួយផ្នែក សម្រាប់បម្រើវិស័យទំនាក់ទំនងក្នុងសង្គមតាមរយៈសំណេររបស់អ្នកករនិពន្ធ។

អត្ថបទកំណាព្យដ៏តូចមួយនេះ ក៏ដូចជាកូនសៀវភៅជាប់នឹងដៃរបស់លោកអ្នក គឺជាការចងក្រងឡើងពីអ្នកកវីស្ត្រីម្នាក់ ឈ្មោះ **លី ឡាវុន** ដែលជាសមាជិកសមាគមអ្នកនិពន្ធមួយរូបព្រមទាំងបានខ្នះខ្នែងបង្កើតជាស្នាដៃនេះ ឡើងមានចំនួន.........ទំព័រ ក្រោមចំណងជើងថា៖ **ព្រះនាងយសោធរាពិម្ពា** គឺជាពាក្យកាព្យដែលឆ្លុះបញ្ចាំងពីសម័យពុទ្ធអង្គទ្រង់នៅជាពុទ្ធិញ្ញាណ។

ការិយាល័យរដ្ឋបាលនៃសមាគមអ្នកនិពន្ធខ្មែរ សូមថ្លែងអំណរគុណចំពោះសមាជិករូបនេះដែលបានប្រសូតជាសៀវភៅនេះឡើង ។ កំណាព្យកាព្យឃ្លោងធ្វើឲ្យរន្ទឹននៃព្រលឹងមនុស្សជាតិដែលបានបង្កប់នូវខ្លឹមសារអក្សរសិល្ប៍ដូចតួយ៉ាងកូនសៀវភៅនេះជាដើម ។ល។

-អក្សរសាស្ត្ររុងរឿង ជាគ្រឿងបំភ្លឺប្រទេស។

-អក្សរសាស្ត្រ ក្លាយជាអក្សរសិល្ប៍ ដរាប អ្នកនិពន្ធចេះប្រើទៅតាមកាលៈទេសៈ។

ភ្នំពេញថ្ងៃទី០១មីនាឆ្នាំ២០១២

**ការិយាល័យរដ្ឋបាលនៃសមាគមអ្នកនិពន្ធខ្មែរ**

ប្រធាន

បណ្ឌិត **ខៀវ កុសល**

# អារម្ភកថា

នាងខ្ញុំ បានតាក់តែងសៀវភៅនេះ ជារឿង **ព្រះមហាថេរីយសោធរាពិម្ពា** ដោយខ្ញុំបានសរសេរជាពាក្យកាព្យ រហូតដល់បញ្ចប់។

សាច់រឿងនេះ ពុំបានរៀបរាប់លំអិត តាមលំនាំសេចក្តី នៃរឿងនោះទេ គឺ សង្ខេប ។

បានជានាងខ្ញុំហ៊ានសរសេរសាច់រឿងព្រះអរហន្តីនោះ ព្រោះនាងខ្ញុំសំអាង ទៅលើសៀវភៅលោកអ្នកប្រាជ្ញខ្លះ ដែលបានដកស្រង់ពីគម្ពីរព្រះត្រៃបិតក មានសៀវភៅពន្លឺពុទ្ធសាសនា សៀវភៅប្រវត្តិសាវិកាភាគ២ ដែលបានរៀប រាប់ពីប្រវត្តិរបស់ ព្រះមហាថេរី ស្រាប់ និងសៀវភៅប្រស្នាពុទ្ធប្បវត្តិ ទើបនាងខ្ញុំដកស្រង់យកតាមចំណុចនីមួយៗ ដែលជាខ្លឹមសារអត្ថន័យក្បោះក្បាយ ដូចជាព្រះសង្ឃនិងធម្មាចារ្យធ្លាប់បានសម្តែងផងដែរ។

ខ្ញុំបានសរសេររាយជាខ្សែរឿង បង្កើតរូបបារម្មណ៍ទៅតាមមនោសញ្ចេតនា និងរចនាអោយមានសម្រស់ផង ដើម្បីបំពីសោតារម្មណ៍លោកអ្នក អាន និងលោកអ្នកស្តាប់ អោយបានរីករាយ និងជាប់ជាកុសលផង ។

ចំពោះកិច្ចការនិពន្ធជាពាក្យកាព្យ នាងខ្ញុំប្រាកដថាមានឆ្គាំឆ្គងខ្លះព្រោះនិពន្ធតម្រូវទៅតាមលំនាំនៃសាច់រឿងដើម ពាក្យបាលី ពាក្យក្សត្រ ឈ្មោះទីកន្លែង និងឈ្មោះតួអង្គផ្សេងដែលពិបាកនឹងរួមផ្សំបញ្ចូលតជាប់ចំណាប់ជួន។ ក្នុងនោះដែរក៏មានឃ្លាតចាកខ្លះ ដូចជា សំលេងឃោសៈ និង អឃោសៈ។

ចំពោះពាក្យពេចន៍ និងចំណាប់ចុងជួនដែលបានខ្វះខាតនោះ សូមលោកអ្នកអានមេត្តាអធ្យាស្រ័យ ។

ការតាក់តែងសៀវភៅនេះនាងខ្ញុំ មានគោលបំណងពិសេស ពីរយ៉ាងគឺ ៖

-ចូលរួមលើកកម្ពស់អក្សរសាស្ត្រ វប្បធម៌ខ្មែរ និងពុទ្ធសាសនា

-បំផុសពី សមត្ថភាពស្ត្រីក្នុងសម័យពុទ្ធកាល ក៏ដូចជាសម័យបច្ចុប្បន្នដែលមានស្ត្រីខ្មែរយើងច្រើនរូបនៅក្នុងពុទ្ធសាសនា មានសមត្ថភាព ទទួលបាននូវធនធានព្រះធម៌ ហើយមានខ្លះបានជាអ្នកគ្រូធម្មាចារ្យ ទៀតផង។

នាងខ្ញុំគ្រាន់តែជាឧបាសិកាម្នាក់មានវ័យជរាពិការ ហើយការយល់ដឹងព្រះធម៌ស្ដួចស្ដើង និងចំណេះដឹងក្នុងការនិពន្ធនៅមានកំរិត ប៉ុន្តែមានឆន្ទៈក្នុងការ សម្រេច បង្កើតជាសៀវភៅនេះ។

អាស្រ័យហេតុនេះ នាងខ្ញុំសូមអធ្យាស្រ័យម្តងទៀត ចំពោះការខុសឆ្គង លើសខ្វះ ឬ ពាក្យពេចន៍ មិនគួរគប្បី ហើយសូមជួយធ្វើការរិះគន់ ដើម្បីកែលំអ តាមរយៈលេខទូរស័ព្ទរបស់នាងខ្ញុំដែលមានស្រាប់។

សូមជូនពរ ដល់លោកអ្នកអានសូមបានជួបប្រទះ នូវអ្វីដែលប៉ងប្រាថ្នា ចេញពីកុសលធម៌ សូមបានសមតាមប្រាថ្នា។

*សូមអរគុណ !*

សៀមរាប ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២

លី ឡារ៉ុន

# ឧទ្ទិស

សូមឧទ្ទិសកុសលចេញពីការនិពន្ធ ជូនដល់លោកអ្នកមានគុណដែលបានចេញចាកលោកទៅហើយ ព្រមទាំងញាតិមាន:

- លោកឪពុក លី គាន - លោកម្ដាយ កី ហួរ - ព្រះគ្រូ ព្រំ សេង
- លោកឪពុក ឈន ទូច - លោកម្ដាយ ផៃ ស៊ាងលី - ស្វាមី ទូច ម៉េងហ៊ែរ
- លោកតា លី គីម - លោកយាយ ស៊ា ប៊ី - បងស្រី លី យុលីវ
- លោកតា អាំង ឌិគី - លោកយាយ លឹម ជាម - លោកអ៊ំ កី យង់
- លោកមា អាំង គឹមលី ហៅ តាក់ -ម្ដាយមីង ស ធីវ - លោក យាយ លឹមចេង
- លោក យាយ លឹមធន - លោកតា លឹម ឡេង - លោកតា អាំង ឌិឡេង
- លោកតា លឹម អេង - លោកមា ឡេង បេ - លោកមា ឡេង ប៊ិន
- លោកមា លឹម បេង - លោកមា ប៉ោ ជន - ម្ដាយមីង កាំង យាក
- បងប្រុស យ៉ុង យ៉ន ហៅ កូរ - ម្ដាយមីង ឡេង អៀច -បងប្រុស គី គុងស៊ុន
-ម្ដាយមីង ឡេង ឈាង -ម្ដាយមីង ឡេង ហ៊ាវ -លោកមា ឌិ គឹមហ៊ុ
-លោកមា អាំង តៃ -លោកមា ឡោ ប៊ី -អ្នកមីង លី សាលីវ

---

**សូមប្រគេន ជូនចែកកុសលដល់ លោកអ្នកមានគុណ ដែលកំពុងមានជីវិតរស់នៅ និងញាតិជាទីស្រលាញ់ ៖**

- ព្រះអង្គគ្រូព្រះមហាវិមលធម្ម សិរី សុវណ្ណោ ពិន សែម
- ឧបាសក លី ហុកទាន - ឧបាសិកា អាំង យុហ៊ាក
- ឧបាសក ឡៃ ស៊ុយហ៊ែរ - ឧបាសិកា លី គានលាន
- ឧបាសិកា កី ចាន់ - ឧបាសិកា អាំង វុនឡាយ
- ឧបាសក លី ធានអ៊ីវ - ឧបាសិកា អ៊ាប ស៊ីវគីម -ឧបាសក ឡេង ឌី
- ឧបាសក គាម គីមកឿន - ឧបាសិកា អាំង តារា -ឧបាសក យង់ ពាក
- ឧបាសក ផន ហុង - ឧបាសក ចាន់ ម៉ារ៉ា -ឧបាសក ឡេង យាន
-ឧបាសិកា ឡេង យី -ឧបាសិកា ឡោ អ៊ិត -ឧបាសិកា ឡេង ជឹង
-កូនៗ ក្មួយៗ ព្រមទាំងក្រុមញាតិមិត្តទាំងអស់ ។

- ខ្ញុំសូមបង្គំ ប្រណម្យហត្ថ ឆ្ពោះព្រះត្រ័យរតន៍ ដោយជ្រះថ្លា
នឹកគុណពុំភ្លេច ផលាណា គុណមហិមា លើសព្វសត្វ ។
- ពេលនេះខ្ញុំបាន ផ្ចិតផ្ចង់គិត គោលដៅគំនិត ប្រណិប័តន៍
តាមចំណេះដឹង ពាក្យគ្រប់ម៉ាត់ បើមានភ្លាំងភ្លាត់ សូមករុណា ។
- លើកប្រវត្តិ រឿងព្រះថេរី កែវកល្យាណី យសោធរា
គឺជាព្រះនាង ស្រីពិម្ពា ក្នុងនគរនា ទេវទហៈ ។
- ព្រះមាតានាម អមិត្តា- ទេវី កន្និដ្ឋា ព្រះសុទ្ធោទនៈ
គឺជាពូជពង្ស វង្សសក្យៈ ព្រះនាងច្យុតចាក សួគ៌ាល័យ ។
- ព្រះនាងប្រសូត ចាកឧទរ នៅក្នុងឆ្នាំច វិសាខជ័យ
ថ្ងៃដប់ប្រាំកើត ពេញបូណ៌មី ដូចអង្គក្សត្រថ្លៃ ព្រះសិទ្ធត្ថ ។
- កាលនាងប្រសូត ចាកឧទរ មានរស្មីពណ៌ ក្រហមរតន៍
នៅនឹងសិរៈ ចាំងព័ន្ធព័ទ្ធ សញ្ញាប្រាកដ មានបារមី។
- ហើយទ្រង់សរុប ព្រះនាមថា ភទ្ទាកញ្ញា ធីតាថ្លៃ
យសោធរា ពិម្ពាស្រី ជាកល្យាណី នារីរតន៍។

\- ភ័ព្វព្រេងវាសនា ពីបុព្វជាតិ ជាគូមិនឃ្លាត មិនដែលព្រាត់
ជាមួយអង្គក្សត្រ ព្រះសិទ្ធត្ថ អង្គពោធិសត្វ មានបារមី ។

\- នាងជាបុត្រី ថ្លៃបរិសុទ្ធ ស្តេចសុប្បពុទ្ធ អង្គក្សត្រថ្លៃ
លុះដល់រូបកាយ ចំរើនវ័យ សម្រស់ល្អក្រៃ គ្មានស្រីផ្ទឹម ។

\- កម្ពស់ឆើតឆោម សមកាយា ទ្រង់ទ្រាយលក្ខិណា ស្រស់ប៉ប្រិម
ទម្រង់ភក្ត្រា ផ្កាញញឹម ស្រីផងរកផ្ទឹម ពុំបានសោះ ។

\- កេសាអន្លាយ ស្លូតខ្មៅយង់ រលើបរលង់ គន់មិនខ្ចោះ
នេត្រាទាំងគូ មុតថ្លាស្រស់ នេះជាសម្ផស្ស ស្រីសួគ៌ា ។

\- ដំណើរល្វតល្វន់ ទន់ទងវង ម្រាមហត្ថទាំងសង ដូចបន្លា
ហត្ថាស្រឡូន ទាំងបាទា ចាំងដោយរោមា ភ្លឺផ្លេកៗ ។

\- បន្ថែមដោយគ្រឿង អលង្ការ សុវណ្ណរតនា ចាំងអនេក
កោសេយ្យពស្ត្រ ល្អពន់ពេក ព្រះកេសម្កុដឯក ថ្លៃកន្លង ។

\- នាសាដាំគ្រាប់ ពេជ្រចរណៃ ហត្ថបាទក្រាស់ក្រៃ គុជកែវកង
រីឯព្រះកាណ៌ យ៉ាណែងណង គន់ព្រះសូរង្គ ចាំងព្រាតៗ ។

- កាយសម្ផស្សឯក ព្រោះកុសល តាក់តែងបានផ្តល់ ពីធម្មជាតិ
បុណ្យខ្ពស់ក្រាស់ក្រៃ លើសមនុស្សជាតិ គឺបុណ្យល្អស្អាត ឥតគណនា ។
- ព្រះនាងជាក-ន្សៀសារពេជ្ជ និស្ស័យល្អផ្តាច់ លើលោកា
និងព្រះសិទ្ធត្ថ អង្គចេស្តា ជាបុត្រក្សត្រា សុទ្ធោទនៈ ។
- កបិលពស្តុនគរ រាជបុរី ព្រះនាមល្បាញល្បី វង្សសក្យៈ
ព្រះអង្គមានឫទ្ធិ ខ្ពស់អនគ្ឃ ស្មើនិងស្តេចចក្រ ចក្រពតិត្រា ។
- ព្រះរូបរស្មី ដូចឥន្ទ្របុត្រ ចុះចាកចរច្យុត មកលោកា
ជាតិពោធិសត្វ ត្រូវបព្វជ្ជា មិនដូច្នោះណា ជាស្តេចចក្រ ។
- ពេលនោះព្រះនាង យសោធរា មាតាបិតា ព្រមស្មោះស្ម័គ្រ
អោយយាងទៅគាល់ អង្គសក្យៈ ព្រះសុទ្ធោទនៈ បិតុលា ។
- កាលយាងដំណើរ គ្រានោះនៃ ប្រកបសិរី ក្តីសុខា
អាមាត្យភិលៀង អមការពារ ដង្ហែត្រៀបត្រា ឥតមានហ្មង ។
- នារីពេញវ័យ ស្រីសោភា កាន់ពានមាលា ផ្កាកម្រង
បុរសបាំងខ្លស់ ស្រស់កន្លង ដង្ហែត្រសង សំដៅនាយ ។

- ចាកទេវទហៈ ដោយរួតរះ ចូលកបិលពស្តុ យ៉ាងរីករាយ
ទិដ្ឋភាព ឧទ្យាន ល្អឆើតឆាយ នាងគន់ជិតឆ្ងាយ ពេញទ័យា ។
- ឯនាយដើមស្រល់ គួរគយគន់ ត្រូវខ្យល់រវន់ ទន់ផោ
គន់ទៅដើមចាន់ ផ្លែគរគ្នា គន់ទៅដើមល្វា មែកក្រសុំ ។
- រីដើមចំប៉ា ផ្កាព្រោងព្រាត ពិដោររសជាតិ សែនមនោរម្យ
ត្រូវនឹងជំនោរ ថ្ងូររហុំ ក្រអូបឆួលងុំ ជ្រាបនាសា ។
- អើតមើលទៅមេឃ មេឃស្រទុំ សុរិយាបាំងភ្នំ សុមេរា
រីឯបក្សី និងបក្សា ហើរតៀងគូគ្នា ឆ្វេលដើមជ្រៃ ។
- សម្លេងរុក្ខជាតិ បក់បន្ត ហាក់ដូចអបអរ ថ្វាយពរជ័យ
ដល់ព្រះដំណើរ អង្គក្សត្រី ទៅភ្ជាប់និស្ស័យ ព្រះសិទ្ធត្ថ ។
- ព្រះនាងចម្លែក ព្រះទ័យខ្លាំង គង់ក្នុងទីនាំង ទតបព៌ត
តាមក្បួនដង្ហែដ៏មធ្យ័ត ព្រះទ័យរសាត់ តាមវាតា ។
- នាងនឹកស្រមៃ អនាគត ហាក់ដូចកម្សត់ក្នុងចិន្តា
ហើយក៏ត្រិះរិះ ពិចារណា ដល់ព្រេងវាសនា កាយជាស្រី ។

- លុះក្សួនដង្ហែ ចរចូលដល់ បានជួបបានយល់ រាជវាំងជ័យ
ចូលគាល់បិតុលា អង្គចក្រី ក្នុងគ្រានោះនៃ មនុស្សខៀវខ្វា ។
- ព្រោះមានពិធី ឱឡារិក អធមអធិក ជ្រើសធីតា
១០០អង្គា យាងតគ្នា បង្ហាញសោភា ព្រះសិទ្ធត្ថ។



- ព្រះរាជកុមារ គង់បល្ល័ង្ក ព្រះកាយព្រះអង្គ ដោយស្ងៀមស្ងាត់
ធីតាគ្រប់អង្គ យាងឆ្លងកាត់ ពិធីការចាត់ ចែកប្រទាន ។
- នូវរង្វាន់ចំនួន ១០០ គឺជាអំណោយ កំណត់មាន
ដល់ពួកធីតាទ្រង់ប្រទាន តែព្រះទ័យគ្មាន ជាប់ចំណង ។
- ចុងក្រោយស្រាប់តែ ទេពធីតា ពិម្ពាកន្និដ្ឋា ស្រស់នួនល្អង
យាងដល់ក្រោយគេ ឥតមានហ្មង ហើយបានសាងសង សុវណ្ណ៍ ។
- ថាព្រះជេដ្ឋា ថ្ងៃឧត្តម រឺខ្ញុំម្ចាស់ខ្ញុំ ខំឃ្មាតខ្មី
ទ្រង់មានរង្វាន់ អំណោយអ្វី ដល់អនុជស្រី ណាឡើមា៉ ។
- ព្រះរាជកុមារ មហាបុរស ភាំងនិងសម្ផស្ស ស្រស់កន្និដ្ឋា
ទ្រង់បានសណ្តាប់ ដូច្នេះណា ក្នុងព្រះឱ៉ា សែនរីករាយ ។
- លាន់ព្រះឱសថា យសោធរា ពេញវ័យសោភា ល្អពណ្ណរាយ
ព្រះទ័យកន្និដ្ឋាពិតទូលាយ បន្ទូលរីករាយណាស់ឆោមយង់ ។
- ហើយទ្រង់ដោះនូវ គ្រឿងសង្ហារ ចេញពីឱ៉ា តាមសុរង្គ ។
ដាំត្បូងមរកត ភ្លឺថ្លាយង់ បំពាក់ សុរង្គ អនុជថ្លៃ ។

- ពេលនោះអង្គក្សត្រីយ៍ សក្យៈវង្ស ត្រេកអរគ្រប់អង្គថាប្រពៃ
សិទ្ធត្ថកុមារ ជួបនិស្ស័យ ពិម្ពាចរណៃ ថ្លៃពិសិដ្ឋ ។
- សិទ្ធត្ថបានយល់ យសោធរា ពោរពេញទ័យា ពន់ពេកពិត
ចាប់គួចប្រតិព័ទ្ធ កែវមិត្រ ពេលបានជួបជិត ស្ម័គ្រមេត្រី ។
- ស្តេចសប្បពុទ្ធ អង្គក្សត្រា ទេវីអមិត្តា មហេសី
និងសុទ្ធោទនៈ ព្រះចក្រី ភ្ជាប់ស្ពានមេត្រី បុត្រទ្វេហា ។
- តែសប្បពុទ្ធ ពេលនោះនៃ ពុំអស់ព្រះទ័យខ្វល់ឱ៉ា
ព្រោះតែពិម្ពា រាជធីតា មានអ្នកប្រាថ្នា ជាគូគ្រង ។
- ទើបព្រះអង្គមាន ព្រះបន្ទូល ក្នុងន័យសម្រួល តាមទំនង
សិទ្ធត្ថកុមារ ល្អកន្លង វិជ្ជាសាស្ត្រផង មានដែរឬ ? ។
- គួរតែបញ្ចេញ នូវវិជ្ជា សិល្បសាស្ត្រនានា បានដឹងឮ
ប្រកួតប្រទ្បង ឲ្យនឹ្ល ឲ្យគេផងលឺ ឃើញចេស្តា ។
- ព្រះសុះទ្ធាទនៈ ទ្រង់សណ្តាប់ ទ្រង់ឆាប់រាយរ៉ាប់ ប្រាប់បុត្រា
ប្រុងប្រៀបសម្តែង សិល្បវិជ្ជា ដើម្បីពិម្ពា ធីតាថ្លៃ ។

- មានគូប្រកួត ដល់បីអង្គ ព្រះបិតាទ្រង់ ព្រួយព្រះទ័យ
ក្រែងសិទ្ធត្ថបុត្រ បរាជ័យ ព្រោះមានវគ្គបី ត្រូវប្រឡង ។
- ព្រះពោធិសត្វ ទ្រង់តម្រិះ វិជ្ជាចំណេះ ជាចម្បង
គឺសមាធិ ឫសកែវហោង វិធីប្រឡង អាចជោគជ័យ ។



- កំណត់ដល់ថ្ងៃ ចេញប្រឡង មនុស្សច្រើនអឹងកង គ្រប់ៗវ័យ
សំដៅចូលដល់ ព្រះលានជ័យ អ្នកខ្លះភិតភ័យ ញ័រតក្កមា ។
- ពិម្ពាធិតា ស្រស់វល័ក្ខ គង់អាសនៈ ឯបបិតា
ព្រះនាងបន់ស្រន់ ក្នុងចិន្តា ឲ្យរាជកុមារ បានជោគជ័យ ។
- ទី១ ផ្តើមបាញ់ ធ្នូរសិល្បសាស្ត្រ លាន់ដូចរន្ទះ ខ្ទរភាល័យ
ទី២ រហស្សកម្ម គុនដាវជ័យ អ្នលមើលភិតភ័យ កោតស្ញប់ស្ញែង។
- ទី៣បញ្ហាសេះប្រណាំង សេះកំណាចខ្លាំង សែនភ័យក្រែង
ព្រះពោធិសត្វ ដូចសូរ្យសែង ឈ្នះគូប្រជែង គ្រប់ទាំងបី ។
- ពិម្ពាត្រេកអរ ឥតឧបមា យល់ព្រះជេដ្ឋា មានបារមី
នាងចាកអាសនៈ ប្រញាប់ខ្មី សំដៅក្សត្រិយ៍ថ្លៃឥតខ្វល់ខ្វាយ ។
- ព្រះនាងបានថ្វាយ ភួងមាលា ក្រងពីម្ទិះផ្កា ក្រអូបសាយ
ដល់ព្រះកុមារថ្លែងក្អាកក្អាយ ទាំងពីរព្រះកាយសមគ្នាណាស់ ។
- ព្រះសប្បពុទ្ធ យល់ចេស្តា សិទ្ធត្ថកុមារ ប្រាកដច្បាស់
ព្រះអង្គសម្រេបឥតក្រឡាស់ ពេញព្រះទ័យណាស់ បុត្រសុណិសា។

- បំប៉ន៏កាមសុខ កាមរាគៈ ដែលជាអន្ទាក់ គោលជំនួយ
ទប់ស្កាត់ខ្លាចជួប សង្វេគព្រួយ គោលដៅតែមួយ គ្រងរដ្ឋា។



- ព្រះនាងទទួល អភិសេក　　រុងរឿងអនេក គ្រប់តម្រា
តាមប្រពៃណី វង្សក្សត្រា　　សប្បាយក្រៃណាក្នុងបុរី ។
- រាជវាំងគឺជា ឋានសួគ៌ា　　ប្រទីបជ្វាលា ចាំងរស្មី
លំអបុប្ផា ពាសពេញដី　　គ្រប់ច្រកទិសទី សែនវិចិត្រ ។
នៅក្នុងប្រាសាទ ព្រះកុមារ　　សម្រស់សន្និយា យ៉ាងប្រណិត
ផ្កាមាសផ្កាប្រាក់ ប៉ាក់ជាប់ស្អិត　　ភិលៀងនៅនិត្យ ថែរក្សា ។
- គន់ទៅសយនា ឃើញលឹមៗ　　ចាំងត្បូងទទឹម សុវណ្ណា
ក្រាលព្រំកម្មញី សូត្ររចនា　　វត្ថុកាមា ជុំវិញកាយ ។
- និងកាយសម្ផស្ស ទេពអប្សរ　　បំពីកំដរ គន់មិនណាយ
វត្ថុជាអន្ទាក់ចិត្តកាយ　　លែងគិតខ្វល់ខ្វាយ សង្វេគធម៌ ។
- ពិធីអភិសេក ដល់បញ្ចប់　　និវត្តន៍ត្រឡប់ ទៅនគរ
អង្គសប្បពុទ្ធ ប្រសិទ្ធិពរ　　ដល់បុត្របវរ ទាំងពីរអង្គ ។
· ហើយទ្រង់ផ្តាំផ្ញើរសុណិសា　　ជួយថែរក្សា អនុជទ្រង់
- ប្រគល់បុត្រី ថ្វាយព្រះអង្គ　　ដើម្បីឲ្យទ្រង់មេត្តាផង ។

- ពូជពង្សវង្សក្សត្រ សែនរីករាយ មកពីជិតឆ្ងាយ ស្ញើចសាសង
ថាព្រះសិទ្ធត្ថ ល្អម្ល៉េះហោង សមនឹងគូគ្រង យសោធរា ។
- លើលោកពុំដែល ជួបយល់សោះ មហាបុរស ស្រស់សោភា
គឺជាឥន្ទ្របុត្រ ចាកសួគ៌ា ទាំងពីរអង្គា ថ្លៃពណ្ណរាយ ។
- នគរកបិលពស្តុ រាជបុរី ថ្កុំថ្កើងខ្លាំងក្រៃ ល្បីសព្វសាយ
ដោយអំណាចបុណ្យ គុណទាំងឡាយ ព្រះទ័យព្រះកាយ ល្អកន្លង ។
- អស់កាលជាច្រើន ព្រះវស្សា ព្រះនាមចេស្តា ល្បីរំពង
ទ្រង់សោយសុខា ឥតមានហ្មង ប្រជារាស្ត្រ សែនសុខសាន្ត ។
- ព្រះនាងពិម្ពា ថ្លៃបវរ នាងមានព្រះគ៌ភ ហើយកល្យាណ
ក្នុងរាត្រីមួយ ព្រះនាងបាន សុបិនរំខាន ភ័យញាប់ញ័រ ។
- ព្រោះសុបិន នាងដ៏អាក្រក់ នាងភ័យស្លឹតស្លក់ ឱបឧទរ
ខ្លាចក្រែងគ្រោះភ័យ ដល់ព្រះគ៌ភ រន្ធត់ញាប់ញ័រ ហើយសោកា ។
- នាងយល់កាត់ សុបិននិមិត្ត ថាប្រាកដពិត នាងមរណា
ពុំចេ្មាះព្រាត់ប្រាស់ ពីភស្តា ចាកចោលពិម្ពា ប្រាកដពិត ។

- ព្រះពោធិសត្វ បានបីបម ល្អងលោម ថ្នាក់ថ្នម កែវមិត្រ
ថាជាសុបិន ពុំមែនពិត ទើបនាងរិះគិត ឈប់ខ្វល់ខ្វាយ។
- កន្លងក្រោយមក គ្រានោះណា ប្រសូត្របុត្រា ស្រស់ឆោមឆាយ
ព្រះទ័យព្រះនាង សែនរីករាយ ញាតិវង្សគ្រប់កាយ សែនសាទរ។
- ព្រះនាងរង់ចាំ ព្រះភស្តា ពុំឃើញយាត្រា មកអបអរ
តាមទឹកព្រះទ័យ ដែលស្មោះស ទតបុត្របវរ គួរបេតី ។
- រីឯអស់ពួក ស្រីភិលៀង បានកំដរច្រៀង ដោយតន្ត្រី
បំពេរអារម្មណ៍ ក្នុងរាត្រី លុះដល់យាមបី ដេកលង់លក់។
- នាងខ្លះដេកផ្ងៀង ខ្លះដេកផ្ងា នាងខ្លះមាត់ហា ថ្ងូរគគ្រក់
នាងខ្លះជិតមុខ រំសាយសក់ នាងខ្លះស្រមុ៊ក គួរអនិច្ចា ។
- ព្រោះតែលង់លក់ ភ្លេចទាំងអស់ នទៀលផើស រូបកាយា
របូតរបើក សារស្បៃយ្យា ខ្លះគងលើគ្នា ពុំដឹងអ្វី ។
- គ្រានោះព្រះអង្គ ពោធិសត្វ ដំណឹងប្រាកដ ពិម្ពាស្រី
នាងប្រសូត្របុត្រ រួចហើយនៃ តែព្រះចក្រី ប៉ងលីលា ។

- ព្រោះព្រះអង្គជួប ភ័យសង្វេគ មិនអាចរារែក នៅផរា
ព្រះអង្គសំរេច សាងបព្វជ្ជា ត្រូវតែចាកលា ចោលមហេសី។



- គ្រានោះឆ្នាំថោះ ខែអសាឍ ព្រះចន្ទល្អស្អាត ពេញបូណ៌មី
ព្រះពោធិសត្វ មានសេរី ត្រូវចាកបុរី ដាច់ទ័យា។
- តែទ្រង់ចាំបាច់ ទតបុត្រសិន មុននឹងចាកចេញ ទៅបព្វជ្ជា
ហើយទ្រង់យាងដល់ ក្នុងប្រាង្គប្រា ទតឃើញហត្ថា មាតាគង ។
- ព្រះអង្គចង់លើក ថ្នមបុត្រា តែខ្លាចពិម្ពា ភ្ញាក់ផ្អើលផង
នឹងនាំឱ្យខក ក្ដីបំណង ហើយក៏យាងឆ្លងចេញ ទៅអើយ ។
- អរុណោទ័យ រស្មីស្រាង អស់ពួកនាងៗ លង់លក់ឡើយ
ជំនោរត្រសៀក ផាត់ផើយៗ លលកបូលឆ្លើយ គួរស្រណោះ ។
- ព្រះនាងបានផ្ទុំ ស្កប់ឱ៉ា បើកព្រះនេត្រា ទតឱរស
ពេលនោះទាសី ចូលដល់ឆ្ពោះ ក្រាបទូលដោយស្មោះ យ៉ាងតក្កមា។
- ថាឱ! អម្ចាស់ អង្គក្សត្រី រីព្រះស្វាមី អង្គក្សត្រា
ព្រះអង្គយាងចាក ពីសីមា សូមទ្រង់ជ្រាបណា ណ៎ាព្រះពរ។
- ពេលនេះនិស្ស័យ តម្រូវចារ ព្រះនាងពិម្ពា ភ័យញាប់ញ័រ
ជ្រាបថាស្វាមី ចាកចេញចរ ចេញពីនគរ អស់និស្ស័យ ។

- នាងឃើញតែបុត្រ បាត់បិតា ភាន់ភាំងហើយណា ក្នុងហឫទ័យ
ថាឱ! ពេលនេះ ខ្ញុំទុក្ខភ័យ ពុំយល់ដឹងអ្វី មូលហេតុសោះ ។



- ចិត្តមួយសង្វេគ គិតបុត្រា ពុំដឹងអ្វីណា នៅឱរស
ឱះឱ!បុត្រអើយ សែនស្រណោះ ពុំដឹងអ្វីសោះ ណ៎ាបុត្រថ្លៃ។
- ព្រះនាងសោយសោក បោកកាយា ថាខ្ញុំពិម្ពា កំហុសអ្វី
បានជាព្រះអង្គ ឥតប្រណី ចោលពិម្ពាស្រី និងបុត្រា។
- ឬ ពិម្ពាខ្ញុំ ស្រីអបលក្ខណ៍ ទ្រង់អស់ក្ដីស្ម័គ្រ ផ្ដាច់ស្នេហា
បានជាព្រះអង្គ ចរយាត្រា ដាច់ក្ដីមេត្តា ដូច្នេះអើយ ។
- ទ្រង់ព្រះកន្សែង ក្ដុកក្ដួលធំ វិយោគយោបំ ពុំមានស្បើយ
ថាឱ! ស្វាមី ខ្ញុំម្ចាស់អើយ ក្នុងពេលនេះហើយ ទុក្ខខ្ញុំម្ចាស់ ។
- ទុក្ខមួយសោកស្ដាយ ព្រះស្វាមី ទុក្ខមួយខ្លួនស្រី សែនអាម៉ាស់
ស្វាមីចាកចោល ដាច់ស្រឡះ ខ្លួនសែនអាម៉ាស់ អស់ញាតិស្រី ។
- រីឯព្រះអង្គ សុទ្ធោទនៈ ព្រះអង្គអួលអាក់ ក្នុងហឫទ័យ
ទ្រង់ពិចារណា សព្វសេចក្ដី ថាតើបុត្រថ្លៃ បំណងអ្វី ។
- ក្នុងនាមជាស្ដេច មហានគរ ម្ដេចបុត្រចេញចរ ឥតប្រណី
ចោលបិតាបុត្រ និងមហេសី តើប្រាថ្នាអ្វី លើសនេះណា ។

- ហើយត្រាស់បញ្ជា ឥតរារង់ តាមស៊ើបព្រះអង្គ ឱ្យឆាប់រ៉ា
ពីសកម្មភាព ហេតុកិច្ចការ តើគង់ទីណា ដើម្បីអ្វី ។
- ឱ្យបានដំណឹង និងម្ទីម្ទា បើនៅយូរយា មានទុក្ខភ័យ
ព្រោះនាងពិម្ពា ជាមហេសី នាងសោកស្ទើរក្ស័យ ទៅហើយណា ។
- ព្រះអង្គចាត់រក ស្ត្រីល្អ ចេះលួងអង្វរ ស័ព្ទវាចា
លួងលោមពិម្ពា បុត្រសុណិសា កំពុងសោកា ដូចអកញី ។
- អាសូរព្រះនាង យសោធរា អួលណែនឱរ៉ា ខ្លាំងឥតបី
មិនសោយក្រយ៉ា និំចំណី ទិវារាត្រី ផ្ទុំពុំបាន ។
- ព្រះនាងទតបុត្រ ស្គតកាយា ហូរទឹកនេត្រា ពុំស្រាកស្រាន្ត
រីឯពួកស្រី ជាកល្យាណ លួងលោមគ្រាន់បាន ទុក្ខរសាត់ ។
- នាងខំរំងាប់ ក្តីទុក្ខា សម្រួលចិន្តា បានស្ងប់ស្ងាត់
កំចាត់ទុក្ខសោក ឱ្យខ្ជាយខ្ជាត់ មិនយូរមិនបាត់ វិលមកវិញ ។
- កន្លងថ្ងៃខែ ឥតខ្លឹមសារ នាងនៅកំព្រា ទ្រូងពោរពេញ
រង់ចាំដំណឹង ទាំងទោម្នេញ ពុំឃើញវិលវិញ សែនអាល័យ ។

- ក្រោយព្រះនាងជ្រាប ដំណឹងថា ព្រះអង្គក្សត្រា ជាស្វាមី
ព្រះអង្គបព្វជ្ជា នៅក្នុងព្រៃ អស់ក្ដីអាល័យ អស់កិលេស ។
- ព្រះនាងសម្រួល ក្ដីឈឺចាប់ ព្រះនាងតម្រាប់ គ្រប់តម្រិះ
យល់ព្រះអង្គមាន គុណវិសេស ស្វែងរកចំណេះ ព្រះធម៌ថ្លៃ ។
- ព្រះនាងតម្រាប់ តាមភស្ដា ពេលបានដឹងថា អង្គក្សត្រថ្លៃ
ផ្ទុំផ្ទាល់ធរណី ពិម្ពាស្រី នាងផ្ទុំផ្ទាល់ដី តាមព្រះអង្គ ។
- ដឹងថាស្វាមី អត់អាហារ ទុក្ករកិរិយា នាងស្រយ៉ង់
ស្រយ៉ុតក្នុងចិត្ត អាណិតទ្រង់ នាងក៏លះបង់ មិនសោយឡើយ។
- ជ្រាបថាព្រះអង្គ គ្រងចីវរ លះបង់ភោទល្អ ជាក្សត្រហើយ
នាងក៏លះបង់ តាមទៀតអើយ ទុក្ខនាងគ្មានស្បើយ យល់បុត្រស្នេហ៍។
- ព្រះទ័យព្រះនាង ព្រួយឥតស្រាន្ត ជលនេត្រប៉ុន្មាន ហូរគ្មានល្ហែ
នាងរងទុក្ខសោក យូរឆ្នាំខែ ខំកាត់ណាស់ដែរ តែមិនបាន ។
- ព្រះរាជឱរស ព្រះនាមថា រាហុលកុមារ បុត្រថ្កើងថ្កាន
កាន់ចម្រើនវ័យ ស្រស់កល្យាណ ព្រះនាងគ្រាន់ស្រាន្ត ទុក្ខសោកា។

- ពេលមួយព្រះអ-រុណរឿងរះ ភ្លឺចាំងស្រឡះ ជះពសុធា
ព្រះនាងគយគន់ ទៅនភា ស្រាប់ឮវាចា ភិលៀងស្រី ។
- បានគាល់ព្រះនាង ថ្លែងទូលថា សាសព្ទវាចា ក្នុងបុរី
ថាអង្គចមភព ព្រះស្វាមី ចូលក្នុងបុរី ថ្ងៃនេះអើយ ។
- ព្រះនាងត្រេកអរ ក្នុងហឫទ័យ រង់ចាំក្សត្រថ្លៃ ពុំភ្លេចឡើយ
ចាំអស់មួយថ្ងៃ ផុតទៅហើយ ពុំទាន់ឃើញឡើយ ព្រះភស្តា ។
- រាត្រីក៏ឆ្លង កន្លងទៀត នាងមុនីនាថ យសោធរា
យាងចេញទតឃើញ មនុស្សខ្មៀវខ្វា ផ្អើលជ្រួលគ្រប់គ្នា ក្នុងគ្រានេះ។
- ថាឃើញពន្លឺ ភ្លឺឥតបី ឆព្វណ្ណរង្សី ល្អអ្វីម្ល៉េះ
មិនដែលឃើញសោះ រស្មីនេះ រន្ទាលប្រចាលប្រែស ផ្អើលគ្រប់ផ្លូវ។
- នេះគឺ រស្មី ព្រះសម្ពុទ្ធ ព្រះអង្គចាកផុត សឹកសត្រូវ
ជាគុណវិសេស គង់ជាប់នៅ ជះបំភ្លឺផ្លូវ ដល់មនុស្សសត្វ ។
- ឆព្វណ្ណរង្សី ប្រាំមួយពណ៌ លឿងក្រហមស ខៀវហង្សបាទ
ព្រះអង្គយាត្រា តាមក្បួនខ្នាត ដើម្បីបិណ្ឌបាត បណ្តាជន ។

- ព្រះអង្គយាងផ្ទាល់ ដោយព្រះបាទ ព្រះភ័ក្ត្រស្រស់ស្អាត គួរគយគន់
ដោយព្រះគុណធម៌ ល្អលើសលន់ ស្វែងរកភោជន បណ្ដាផ្ទះ ។
- យសោធរា ពិម្ពាស្រី សួរទៅទាសី ដោយអន្ទះ
ម្ដេចមនុស្សផ្អើល ច្រើនក្រៃក្រាស់? ទាសីយល់ច្បាស់ ហើយទូលថ្វាត់។
- បពិត្រព្រះនាង ម្ចាស់នៃខ្ញុំ មនុស្សកកកុំ ច្រើនពេកក្ដាត់
គេមើលព្រះអង្គ យាងបិណ្ឌបាត សូមព្រះនាងជ្រាប ណាក្សត្រី។
- នាងទតពីឆ្ងាយ ជាក់ពិតច្បាស់ ស្លុតរន្ធត់ណាស់ សព្វឥន្ទ្រីយ៍
នាងយាងចរចូល ទូលថ្វាបី ព្រះអង្គចក្រី សុទ្ធោទនៈ ។
- ព្រះនាងទំនួញ រៀបរាប់ថា ឱ!ព្រះបិតា អង្គសក្យៈ
ពេលនេះអយ្យបុត្រ អង្គក្សត្រៈ យាងចរចូលជាក់ ហើយព្រះអង្គ។
- ព្រះអង្គត្រាច់ចរ ស្វែងបិណ្ឌបាត តាមផ្ទះគ្រប់ញាតិ តាមចំណង់
ខ្ញុំម្ចាស់ឃើញច្បាស់ ណាព្រះអង្គ ពិតណាស់សូមទ្រង់ បានជ្រាបណា។
- ម្ដេចឡើយព្រះអង្គ បំភ្លេចអស់ ព្រះនាមខ្ពង់ខ្ពស់ យសក្សត្រា
ត្រកូលសក្យៈ ព្រះបិតា មានឫទ្ធីចេស្ដា ថ្លៃរន្ទី ។

- ពេលនោះព្រះបាទ សុទ្ធោទនៈ ទ្រង់បែរព្រះភ័ក្ត្រ សណ្ដាប់ឮ
  លាន់ព្រះឱសថា ពិតមែនឬ ? ពេលនេះខ្ញុំឈឺ ព្រះទ័យណាស់។
- ហើយក៏បានយាង ឆាប់ម្ទីម្ទា ត្រាច់ចរលើលា ដោយរួតរះ
  ទតឃើញពីឆ្ងាយ ប្រាកដច្បាស់ ទ្រង់រន្ធត់ណាស់ ពិចារណា ។



- ឱះឱ! អយ្យបុត្រ បុត្រថ្លៃអើយ បិតាយល់ហើយ គុណសីលា
មិនគួរដាក់កាយ ដូច្នេះណា បុត្រខ្វះភត្តាហារ ណាស់ឬអី?។
- ទោះបីបើត្រូវ ខ្វះខាតខ្លាំង គួរចូលរាជវាំង មានសេរី
គិតផងយាងផង ជួបដល់ខ្មី ទើបព្រះចក្រី បន្ទូលថា ។
- ឱ! ព្រះអយ្យបុត្រ បុត្រល្អស្អាត មិនគួរបិណ្ឌបាត ដូច្នេះណា
ខ្ញុំមិនខ្សត់ទេ ភត្តាហារ ព្រះសង្ឃប៉ុណ្ណា មិនខ្វះខាត ។
- ពេលនោះព្រះអង្គ ព្រះភគវា ទ្រង់បន្ទូលថា កិច្ចបិណ្ឌបាត
គ្រប់ព្រះពុទ្ធអង្គ តែងសង្វាត ត្រាច់ចរបិណ្ឌបាត រស់ជីវិត ។
- ដើម្បីបានប្រោស សាធុជន គ្រប់ទីតំបន់ ទាំងឆ្ងាយជិត
ដាក់ទានអោយខ្ញុំ រស់ជីវិត កើតកុសលពិត តាមជ្រះថ្លា ។
- ពេលនោះព្រះបាទ សុទ្ធោទនៈ ទ្រង់បានជ្រាបជាក់ គុណមេត្តា
របស់អយ្យបុត្រ ថ្លៃមហិមា ជាព្រះភគវា អង្គសម្ពុទ្ធ ។
- រីឯយសោ-ធរាស្រី ពុំសុខព្រះទ័យ នឹកឆ្អក់មុត
គង់ក្នុងប្រាសាទ នៃបនិត្យបុត្រ ចាំព្រះចមម្កុដ ម្ចាស់ជីវិត ។

- គង់ក្នុងនគរ ថ្ងៃទីពីរ អង្គព្រះមុនី ថ្លៃពិសិដ្ឋ
សំដែងទេសនា បារមីឫទ្ធិ ព្រះញាតិជុំជិត ថ្វាយភត្តាហារ។
- ទ្រង់សំដែងធម៌ បន្ថែមទៀត ប្រោសអស់ពួកញាតិ គ្រប់ខ្លឹមសារ
បាត់តែព្រះនាង យសោធរា ពេលនោះបិតា បានត្រាស់រក ។
- ព្រះអង្គប្រើស្រី ឈ្មោះបេសកា ទៅទូលពិម្ពា ឱ្យយាងមក
ព្រះនាងកំពុង ថ្លែងទុក្ខសោក ស្រណោះស្រណោក ឱ៉ាឈឺ ។
- ថាព្រះអម្ចាស់ អស់មេត្តា ដាច់ក្តីស្នេហា ពិម្ពាឬ ?
ទ្រង់អស់អាល័យ មិនដឹងឮ ទុកពិម្ពានៅ ដោយកំព្រា ។
- ជាមួយនិងបុត្រ ទុក្ខក្រៀមក្រំ រស់ដោយបង្ខំ ទ្រូងរងា
អស់ពេលយូរឆ្នាំ ចាំភស្តា ចេញសាងបព្វជ្ជា ដោយលះបង់។
- មកដល់បេសកា បានទូលថា ក្នុងពេលនេះណា ព្រះចមពង្ស
ព្រះអង្គទេសនា ប្រោសញាតិវង្ស កំពុងបិតគង់ លើសន្និវេសន៍ ។
- បិតាបានឱ្យ ទូលព្រះនាង សូមបានឆាប់យាង ក្នុងពេលនេះ
ព្រះនាងតបថា ទ្រូងខ្ញុំប្រេះ នៅក្នុងពេលនេះ ហើយណាស្រី។

- ព្រះនាងគក់ទ្រូង ថ្លែងទូលថា ខ្ញុំស្រីឫស្យា កាឡកិណ្ណី
ឥន្ទ្រីយ៍វិកល មិនប្រក្រតី ឡើងគាល់ចក្រី អាប់ចេស្តា ។
- ដើមឡើយព្រះអង្គ ធ្លាប់រួមនៅ ម្តេចក៏ឥឡូវ ព្រះភស្តា
យាងមកដល់ហើយ ប្រែក្រឡា ឱ្យខ្ញុំពិម្ពា ទៅគាល់វិញ ។
- ព្រះនាងរ៉ាយរ៉ាប់ ប្រាប់បេសកា ឱ្យទូលបិតា ពីទុក្ខម្នេញ
ថាពិម្ពាសូម លាចាកចេញ លាស្លាប់ទៅវិញ ថ្ងៃនេះហើយ ។
- ព្រះសុទ្ធោទនៈ ដឹងហេតុការណ៍ តាមរាយរ៉ាចា បេសកាហើយ
ទ្រង់ទូលព្រះពុទ្ធ មិនកន្តើយ រៀបរាប់អស់ហើយ ពីទ័យា ។
- កាលដែលព្រះអង្គ យាងចាកចោល នាងនៅតែលតោល ទុក្ខក្រំគ្រា
នាងសាងគុណធម៌ តាមភស្តា តែក្តីទុក្ខា មិនបាត់បង់ ។
- ពេលនេះសូមអារាធនានិមន្ត សូមទ្រង់រួសរាន់ កុំបង្អង់
ទៅរកព្រះនាង កំពុងទ្រង់ សោយសោកឯកអង្គ លង់សង្ខារ។
- ព្រះអង្គសម្ពុទ្ធ បានតម្រាស់ វេលានេះច្បាស់ ស្រីពិម្ពា
បើទ្រង់មិនយាង បែកឱរ៉ា ពិតជាមរណា អសារបង់ ។

- ព្រះអង្គទ្រង់មាន បន្ទូលថា បើនាងពិម្ពា គាល់ព្រះអង្គ
ឱបព្រះបាទា តាមចំណង់ ព្រោះតែព្រះអង្គ លើកទោសា ។
- ហើយទ្រង់យាងកាន់ ប្រាសាទនាង ហើយទ្រង់ប្រទាន បាតបិតា
អោយស្តេចយាងទៅ តាមផងណា ចូលដល់ប្រាង្គប្រា ឥតរារង់ ។
- ព្រះអង្គទ្រង់គង់ អាសនៈថ្លៃ ហៅឱ្យទាសី ស្រីឆោមយង់
យាងព្រះនាងចេញ កុំបង្អង់ ព្រះសាស្តាទ្រង់ យាងដល់ហើយ ។
- ទាសីបានចូល យាងពិម្ពា ថាព្រះភគវា យាងមកអើយ
សូមព្រះនាងយាង កុំយូរឡើយ ព្រះនាងជ្រាបហើយ ចេញរួសរាន់ ។
- ព្រះនាងយាងចេញ ទាំងក្អុកក្អួល ហើយបានសម្រួល កាយទន់ភ្លន់
ឱនក្រាបទូលគាល់ ទាំងអាក់អន់ នេត្រាជោរជន់ កើតខ្សឹកខ្សួល ។
- ព្រះនាងបានឱប ព្រះបាទា យកព្រះកេសា ទ្រាប់ប្រមូល
រួចថ្លែងរៀបរាប់ តាមបន្ទូល សព្វគ្រប់ខ្សឹកខ្សួល អួលសោកា ។
- ថាឱ ! ភស្តា អម្ចាស់អើយ ពិម្ពាគ្មានស្បើយ ទុក្ខសោកា
រស់នៅកំព្រា នឹងបុត្រា ទុក្ខធ្ងន់ក្រៃណា ណាព្រះអង្គ ។

- ទុក្ខមួយអាម៉ាស់ ឈ្មោះមេម៉ាយ ទុក្ខមួយសោកស្តាយ ព្រាត់បាត់បង់
  ទុក្ខមួយភ័យព្រួយ អាណិតទ្រង់ គង់នៅឯកអង្គ ក្នុងព្រៃភ្នំ ។
- ទិវារាត្រី ក្រៃរឮក ភ្លៀងផ្គរគគ្រឹក លាន់គ្រំៗ
  នឹកដល់ស្វាមី ឱអ៊ាំងអំ មានតែទូញយំ សែនអនិច្ចា ។
- អង្គព្រះសាស្តា ទ្រង់ជ្រាបច្បាស់ នាងរលឹកណាស់ ព្រះភស្តា
  កាយបុថុជ្ជន អវិជ្ជា កិលេសតណ្ហា ស្រេះឥន្ទ្រីយ៍ ។



- ព្រះទ័យព្រះអង្គ ប្រោសមេត្តា និងករុណា ដល់ក្សត្រី
នូវភាពឆ្តាំឆ្គង ព្រោះភក្តី ទើបបន្ទូលខ្មីទៅបិតា។
- ថាតែពុំ តែជាតិ នេះប៉ុណ្ណោះ ពិម្ពាស្ម័គ្រស្មោះ នឹងភស្តា
គ្រប់ជាតិដែលបាន រួមវាសនា នាងស្មោះក្រៃណា នឹងស្វាមី។
- ទើបព្រះអង្គទ្រង់ បានសម្តែង រឿងជាតកចែង ចន្ទកិន្នរី
សម្តែងពិស្តា ព្រោះដើម្បី បន្ទោរបង់ក្តី ទុក្ខអកុសល ។
- ទ្រង់សម្តែងចប់ ធម្មទេសនា ព្រះនាងពិម្ពា ទ្រង់ជ្រាបយល់
សម្រេចសោតា បត្តិផល រសាយកង្វល់ ក្នុងឱរ៉ា ។
- រសាយព្រះទ័យ ធ្លាប់អួលអាក់ ដែលធ្លាប់ជំពាក់ កាមតណ្ហា
ស្រឡះអារម្មណ៍ កើតជ្រះថ្លា ស្ងប់ក្នុងកាយា ឥតមានហ្មង ។
- នាងក្រឡេកយល់ រាហុលបុត្រ ព្រះទ័យស្រយុត ពេកកន្លង
នឹកថាឱះឱ! បុត្រស្នេហ៍ស្នង ពេលនេះទៅហោង មានវាសនា។
- បុត្រមិនកំព្រា ដូចមុនឡើយ ជួបបិតាហើយ ណាបុត្រណា
ព្រះអង្គមានបុណ្យ ឫទ្ធិចេស្តា ព្រះទ័យជ្រះថ្លា ឥតគណនា

- ព្រះនាងសសើរ នូវព្រះគុណ ខ្ពង់ខ្ពស់អនន្ត អង្គភគវា
ព្រះទ័យពោរពេញ ក្តីករុណា ប្រោសសត្វគ្រប់គ្នាលើសកល ។



- កន្លងនៅថ្ងៃ ទីប្រាំពីរ អង្គព្រះមុនី ទ្រង់យាងដល់
ព្រះនាងយសោ ទ្រង់បានយល់ ត្រាស់ហៅរាហុលដោយរីករាយ ។
- ហើយបានចង្អុល ប្រាប់បុត្រថា បុត្រទតបិតា ណាឆោមឆាយ
បិតាបុត្រយាង មកដល់អាយ រីករាយសប្បាយ ណាបុត្រអើយ។



- ព្រះនាងរីករាយ ក្នុងព្រះទ័យ ប្រញាប់វិលវៃ មិនយូរឡើយ
  នាំបុត្រស្រោចស្រព គង្គាហើយ វាចាឆ្លងឆ្លើយ ដោយស្នេហា។
- ព្រះនាងសំអិត សំអាងកាយ ឱ្យបានឆើតឆាយ គាល់បិតា
  ហើយត្រាស់បង្គាប់ ដល់បុត្រថា ត្រូវយល់ណាបា កុំសង្ស័យ ។
- ថាព្រះបិតា របស់បុត្រ មានបុណ្យបំផុត លើផែនដី
  ព្រះកាយព្រះអង្គ ដោយរស្មី ព្រះសង្ឃច្រើនក្រៃ ហែរគៀបត្រា ។
- ព្រះអង្គបព្វជ្ជា ចាកវង្សក្សត្រ ព្រះអង្គកំចាត់ អស់តណ្ហា
  មានតែបុត្រទេ ស្នងក្សត្រា តពីជីតា នៅថ្ងៃមុខ ។
- មាតាឮច្បាស់ ហើយចាំជាប់ បិតាមានទ្រព្យ កំណប់ទុក
  ទុកជាមតក៍ តទៅមុខ បិតាមិនទុក ធ្វើអ្វីណា ។
- បុត្រគួរគោរព សុំប្រទាន ទុកដាក់ឱ្យមាន ទុកការពារ
  មាតាមិនដែល ឃើញសោះណា គ្រាន់ដឹងច្បាស់ថា កំណប់មាន ។
- កាលនោះរាហុល ជាបុត្រា ចូលគាល់បិតា ព្រះទ្រង់ញាណ
  ហើយក្រាបទូលសុំ ប្រោសប្រទាន កំណប់ដែលមាន ក្នុងទំនុក ។

- តាមព្រះមាតា បានរៀបរាប់ គឺកំណប់ទ្រព្យ នឹងត្រៀមទុក
សំរាប់ជាទាន នៅថ្ងៃមុខ រាហុលចាំទុក និងជឿជាក់។



- ហើយបន្ថែមក្រាប ទូលទៀតថា ខ្ញុំរាហុលបា ពិតស្មោះស្ម័គ្រ
  បន្តមត៌ក អង្គសក្យៈ ជាអង្គក្សត្រៈ រាជភិសេក ។
- បានជាអង្គស្តេច ចក្រពត្តិត្រា ពេលនេះត្រូវការ ទ្រព្យពន់ពេក
  ទ្រព្យព្រះបិតា ច្រើនអនេក គ្រាន់ជួយរំលែក ទុក្ខរាស្ត្រផង ។
- ព្រះអង្គចមភព ជ្រាបបន្ទូល ព្រះទ័យសំរួល ឥតមានហ្មង
  ព្រះអង្គពុំត្រាស់ តបតហោង ហើយមានបំណង យាងត្រឡប់។
- កាលនោះរាហុល រាជកុមារ យាងតាមបិតា ដោយស្ងៀមស្ងប់
  រហូតដល់វត្ត ទីបញ្ចប់ ឱនកាយគោរព ព្រះបិតា ។
- ព្រះអង្គសម្ពុទ្ធ ទ្រង់ត្រិះរិះ ថារាហុលនេះ ប៉ងប្រាថ្នា
  ចង់បានមត៌ក ទ្រព្យអ្វីណា ទ្រព្យវដ្តសង្សារ ចង្អៀតស្រេះ ។
- តថាគតមាន តែអរិយទ្រព្យ ទ្រព្យប្រសើរគាប់ លើលោកនេះ
  ជាទ្រព្យចំលង ផ្តាច់កិលេស គឺទ្រព្យពិសេស ប្រាំពីរប្រការ ។
- ដែលតថាគត ស្វែងរកបាន ដោយបញ្ញាញាណ គ្រប់ខ្លឹមសារ
  ពីក្រោមពោធិព្រឹក្ស ថ្ងៃនោះណា មត៌កបិតា ត្រូវប្រទាន ។

- បុត្រត្រូវទទួល ទ្រព្យនេះណា ទ្រព្យមហាថ្លៃថ្លា បិតាមាន
  បុត្រទទួលហើយ រួចទុក្ខបាន នៅទីអវសានព្រះនិព្វាន។



- ហើយត្រាស់បង្គាប់ ព្រះសារីយបុត្ត បំបួសកុលបុត្រ បុត្រកល្យាណ
  រាហុលក្លាយជា សាមណេរបាន ព្រះជន្មទើបមាន ប្រាំពីរខួប ។
- សាមណេររាហុល ថ្លៃបវរ គ្រងនូវចីវរ សមព្រះរូប
  ទើបមានព្រះជន្ម ប្រាំពីរខួប ព្រះភ័ក្ត្រព្រះរូប សមប្រពៃ ។
- ស្ថិតក្នុងសំណាក់ ព្រះឧបជ្ឈាយ៍ អង្គអរហន្តា ព្រះសារីយ៍
  ទ្រង់ប្រឹងប្រតិបត្តិ ព្រះវិន័យ រក្សាព្រះទ័យ បានជ្រះថ្លា ។
- យសោធរា នារីរតន៍ នាងជ្រាបប្រាកដ ថាបុត្រា
  បានចូលសាងផ្នួស តាមបិតា នាងគង់ឯកា អនិច្ចាកាយ ។
- នាងខំរំងាប់ ក្តីអាល័យ ចំពោះបុត្រថ្លៃ មិនចេះណាយ
  បុត្រតែមួយអង្គ ចាកចោលម្តាយ ម្តេចបុត្រឆោមឆាយ ដាច់ព្រះទ័យ ។
- មាតាម្នាក់ឯង រ៉ែងតែលតោល ស្វាមីចាកចោល បានបុត្រថ្លៃ
  នេះបុត្របួសទៀត អស់សង្ស័យ នឹកដល់បុត្រថ្លៃ សែនអួលអាក់។
- អនិច្ចំ រូបំអនត្តា ពុទ្ធៈបិតា សុទ្ធោទនៈ
  ព្រះកាយទ្រុឌទ្រោម មិនអមតៈ ព្យាធិលង់ធ្លាក់ ដល់សង្ខារ ។

- ពេលនោះសម្តេច ព្រះទ្រង់ញាណ ទ្រង់បានប្រទាន ធម៌ទេសនា
  ព្រះធម៌ត្រៃលក្ខណ៍ ដ៏ពិស្តារ អនិច្ចំ អនត្តា សម្រេចដល់ ។
- ព្រះអង្គបានចាក ទុក្ខវេទនា ព្រះទ័យជ្រះថ្លា ស្ងប់ឈ្វេងយល់
  ទ្រង់បានសម្រេច អរហត្តផល បានយាងឈានដល់ បរិនិព្វាន។
- កន្លងឆ្លងមក គ្រានោះនៃ បជាគោតមី ស្រីកល្យាណ
  ស្វាមីបញ្ចប់ ចាកចោលឋាន បរិនិព្វាន ផុតទៅហើយ ។
- ព្រះនាងបានស-ម្រេចព្រះទ័យ ប្រញ៉ាប់ឃ្មាតខ្មី មិនយូរឡើយ
  ចេញយាងទៅបួស គ្រានោះអើយ កុសលកើតហើយ ម្ចាស់ក្សត្រី។
- មានទាំងស្ត្រី ប្រាំរយទៀត ដែលជាព្រះញាតិ ក្នុងបុរី
  បួសក្នុងសំណាក់ ព្រះជិនស្រី ក្នុងនាមស្ត្រី ពុទ្ធសាសនា ។
- រីឯព្រះនាង ពិម្ពាស្រី ដឹងច្បាស់ក្សត្រី ព្រះមាតុច្ឆា
  បានចេញសាងផ្នួស តាមប្រាថ្នា សាងគុណសីលា ដំបូងគេ ។
- ពេលនោះព្រះនាង ឥតរុញរា សម្រេចទ័យា មិនងាករេ
  ត្រូវចេញសាងផ្នួស មិនស្ទៀមទេ ថាបើទំនេរ ឥតទីពឹង ។

- ស្វាមីចាកចោល កាលយូរយារ ឯរាហុលបា ក្មេងប៉ុណ្ណឹង
បួសចោលព្រះនាង អស់ពំនឹង នាងត្រូវចេញពឹង ព្រះធម៌ថ្លៃ ។
- ព្រះនាងចេញបួស តាមក្ដីប៉ង សម្រេចបំណង ជាបច្ច័យ
នៅក្នុងសំណាក់ បតិគោតមី បានជួបបុត្រថ្លៃ និងសាស្ដា ។
- ព្រះទ័យមានតែ បុណ្យកុសល អស់នឹកគិតដល់ រាហុលបា
និងព្រះជិនស្រី សាស្ដាចារ្យ សាងគុណសីលា បរិសុទ្ធ ។
- ព្រះនាងធ្លាប់មាន ព្រះរោគា ធ្លាប់ត្រាស់បញ្ជា រាហុលបុត្រ
ដើម្បីនឹងរក បានឱសថ ព្យាបាលរួចផុត ពីកាយា ។
- ព្រះនាងព្យាយាម ដោយស្មោះស បដិបត្តិព្រះធម៌ វិបស្សនា
ចំរើនកម្មដ្ឋាន យ៉ាងក្លៀវក្លា បានសម្រេចជា អរហន្តី ។
- ព្រះអរិយៈ ខ្ពស់បំផុត ប្រសើរមុះមុត លើសថេរី
បញ្ញាកុត្តរៈ គុណបារមី សម្រេចជោគជ័យ គ្រប់វេលា ។
- ព្រះនាងតំកល់ សមាធិ ច្បាស់នូវពុទ្ធិ អភិញ្ញា
ស្ដែងអតីតៈ ជាតិនានា រយសែនកប្បាការ អសង្ខេយ្យ ។

- ជាតិនេះគឺជាតិ អវសាន បញ្ចប់ភពឋាន ចប់ទុក្ខភ័យ
  ព្រះទ័យបរិសុទ្ធ មហាថ្លៃ ព្រះធម៌ក្រាស់ក្រៃ ស្រោបកាយា។
- ព្រះនាងនឹកគុណ ព្រះសម្ពុទ្ធ គុណធ្ងន់បំផុត ឥតឧបមា
  ព្រះនាងទទួល ក្តីករុណា ចាកផុតទុក្ខា គ្រោះប្រល័យ។



- ព្រះនាងមុតធ្ងុះ ព្រោះកុសល បន្ទំបានដល់ ផលនិស្ស័យ
  កន្សែសារពេជ្ជ អង្គអរិយ៍ សន្សំគូដៃ និងភស្តា ។
- គ្រានោះសម្តេច អង្គសម្ពុទ្ធ ព្រះអង្គជ្រាបមុត យសោធរា
  ព្រះអង្គតាំងតែង តំណែងជា ឯតទគ្គៈអស្ចារ្យ អរហន្តី ។
- ព្រះអង្គតាំងនាម ព្រះនាងថា ភទ្ទាកញ្ចនា អង្គថេរី
  ប្រសើខ្ពង់ខ្ពស់ លើសភិក្ខុនី ឯតទគ្គៈបារមី ជាងសាវ័ក ។
- ផែនដីសកល ចេះតែវិល វិលមិនចេះខ្ជិល ក្រឡាប់ចក្រ
  មនុស្សលោក មនុស្សសត្វក្នុងវដ្តៈ ជួបនិងបែកបាក់ ជាធម្មតា ។
- អវសានរាហុល អង្គអហន្ត កើនបានព្រះជន្ម សាមវស្សា
  ពោរពេញគុណ ធម៌ល្អថ្លៃថ្លា មិនគង់យូរយា លើផែនដី ។
- ព្រះអង្គទ្រង់ បញ្ចប់សង្ខារ ថ្វាយបង្គំលា ព្រះជិនស្រី
  និងព្រះមាតា អរហន្តី សូមទានប្រណី យាងនិព្វាន ។
- ព្រះអង្គសម្តែង ឫទ្ធិចេស្តា ដល់តាវតឹង្សា សួគ៌ពិមាន
  រំលត់បញ្ចក្ខន្ធ លំដាប់ឈាន បរិនិព្វាន ដោយបារមី ។

- កន្លងឆ្លងទៅ ម៉្លេវស្សា ភទ្ទាកញ្ញានា អង្គថេរី
ព្រះជន្មឈានដល់ ចិតប្រាំបី ដោយបុណ្យបារមី អមទ្រទ្រង់ ។
- ស្មារតីព្រះនាង គង់នឹងនរ មានគោលជំហរ ល្អគង់វង្ស
ព្រះកាយជរា មិនរារង់ ព្រះធម៌ផូរផង់ មិនរសាយ ។
- ព្រះនាងយល់ច្បាស់ ពីសង្ខារ បញ្ចប់ពិតណា នឹងបែកធ្លាយ
កុសលល្អផ្កាច់ ពីព្រេងនាយ ដូចពេជ្រពណ្ណរាយ អភិញ្ញា ។



- ហើយយាងចូលដល់ ព្រះជិនស្រី ប្រាកដដើម្បី បង្គំលា
និងខមាទោស គ្រប់ប្រការ ហើយនិងនមស្ការ ចូលនិព្វាន។
- ព្រះនាងឱនកាយ ថ្វាយបង្គំ ថាខ្ញុំម្ចាស់ខ្ញុំ មិននៅមាន
លើករឿងអតីតៈ មកនិទាន ដែលខ្ញុំម្ចាស់បាន អភិញ្ញា ។
- ព្រះនាងរៀបរាប់ ជាតិបានកើត អន្ទោលកំណើត បានជួបគ្នា
ជាមួយភស្តា ជាតិនានា រាប់សែនកប្បាការ អសង្ខេយ្យ ។
- ព្រះនាងនិទាន សព្វសេចក្តី ថាគុណបារមី ជាប់និស្ស័យ
ព្រះនាងមានខុស កំហុសអ្វី សូមទ្រង់ប្រណី ប្រទានទោស ។
- និងខមាទោស ផងទាំងឡាយ ប្រព្រឹត្តដោយកាយ កន្លងហួស
ខ្ញុំម្ចាស់បង្គំ សុំលាទោស សូមទ្រង់សណ្តាស ប្រោសប្រណី។
- ព្រោះខ្ញុំម្ចាស់ត្រូវ ចប់សង្ខារ ព្រះជន្មវស្សា ចិតប្រាំបី
រូបកាយទ្រុឌទ្រោម ប្រយោជន៍អ្វី ខន្ធប្រាំដល់ទី ត្រូវរលត់ ។
- ខ្ញុំម្ចាស់ប្រព្រឹត្ត ដោយគោរព តាមព្រះចមភព បានកំណត់
ហើយបានសម្រេច មិននឿយហត់ ដល់ទីកំណត់ ក្នុងពេលនេះ ។

- ខ្ញុំម្ចាស់ផុតអស់ អាសវៈ កំទេចចោលខ្ទាក់ កាមកិលេស
នៅតែកុសល គុណវិសេស សង្ខេបប៉ុណ្ណេះ សូមករុណា ។
- បពិត្រចមម្កុដ បំផុតលោក ខ្ញុំម្ចាស់មានជោគ ជាតិនានា
មានតែព្រះអង្គ សាស្តាចារ្យ គុណធំក្រៃណា ពុំស្មើរឡើយ ។
- បានទីពឹងពាក់ ស្នាក់អាស្រ័យ សត្វលើលោកីយ ឥតកោះត្រើយ
ទាំងព្រហ្មទេវតា គ្មានសល់ឡើយ ព្រះអង្គនេះហើយ សាស្តាចារ្យ ។
- គ្រានោះអង្គព្រះ មុនីនាថ ព្រះអង្គទ្រង់ជ្រាប សព្វវាចា
ព្រះនាងភទ្ទា កញ្ញានា ព្រះអង្គត្រាស់ថា ម្នាលថេរី ។
- គុណតថាគត ទាំងអស់ណា គ្រប់ជាតិនានា ជាប់និស្ស័យ
សន្សំបារមី ច្រើនក្រាស់ក្រៃ នាងជាកន្សែ -សារពេជ្ញ ។
- នាងគ្មានកំហុស ខុសឆ្គងឡើយ នាងប្រាកដហើយ បានសម្រេច
នាងចប់បញ្ចក្ខន្ធ ដែលបានផ្តាច់ នាងបានសម្រេច កាត់ត្រៃភព ។
- គ្រានោះព្រះនាង ថ្វាយបង្គំ ថាខ្ញុំម្ចាស់ខ្ញុំ ជ្រកក្រោមម្លប់
នៃព្រះបារមី ព្រះចមភព ខ្ញុំម្ចាស់បញ្ចប់ បង្គំលា ។

- លាចប់កំណើត ចប់និស្ស័យ ចប់ជាស្វាមី ជាភរិយា
លាចប់ជាបុត្រ ចប់មាតា ចប់វដ្តសង្សារ ចប់វេរា ។
- ពេលនោះព្រះអង្គ ព្រះមុនី តបបន្ទូលខ្មី ទៅពិម្ពា
ថាម្នាលថេរី កញ្ញា សាសព្ទវាចា ប្រាកដពិត។



- ពេលនេះថេរី សម្រួលកាយ មុននឹងបែកធ្លាយ នៃជីវិត
ត្រូវតែសម្តែង ទាំងអស់ឫទ្ធី នូវធនធានពិត ដែលនាងមាន។
- ព្រះនាងសម្តែង ឫទ្ធីទាំងឡាយ បញ្ចេញច្បាស់ថ្វាយ ព្រះទ្រង់ញាណ
គ្រប់អាការៈ ទាំងប៉ុន្មាន ដែលសម្រេចបាន ដោយបរិសុទ្ធ។
- ព្រះនាងក៏បាន ថ្វាយបង្គំ លាព្រះបរម អង្គសម្ពុទ្ធ
ចូលកាន់ទីឋាន ដោយលំអុត ព្រះទ័យបរិសុទ្ធ ដោយធម្មា ។
- ទម្រេតព្រះកាយ ដោយស្ងប់ស្ងាត់ ឈានសមាបត្តិ ឆ្លងសង្ខារ
ទ្រង់ព្រះនិព្វាន គ្រានោះណា ចាកវដ្តសង្សារ ដាច់ស្រឡះ ។
- ពេលនោះរុក្ខជាតិ ស្ងាត់ជ្រងំ ហាក់ដូចក្រៀមក្រំ សង្វេគណាស់
ចន្ទពេញបូណ៌មី ចែងត្រចះ បំភ្លឺយ៉ាងច្បាស់ ផ្ទៃលោកា ។
- វត្តនិគ្រោធារាម វត្តនាមល្បី មានព្រះថេរី ញាតិវង្សា
បួសក្នុងសំណាក់ ព្រះសាស្តា អង្គខ្លះបានជា ខីណាស្រព ។
- អស់ព្រះថេរី បានជួបជុំ ធ្វើកិច្ចបង្គំ ដោយគោរព
គ្រប់អង្គសង្វេគ ដល់ព្រះសព ពិធីបញ្ចប់ កន្លងទៅ ។

- រូបំ អនិច្ចំ អនត្តា ជ្រោះវដ្ដសង្សារ មហាជ្រៅ
អ្នកប្រព្រឹត្តខុស ចុះរណ្ដៅ អ្នកប្រព្រឹត្តត្រូវ ពឹងត្រ័យរតន៍ ។
- អំណាចសេដ្ឋី មន្ត្រីស្ដេច មិនអាចរេះគេច ពីប្រាសព្រាត់
មច្ចុសង្គ្រាម មិនឱនអត់ ហើយមិនកំណត់ នៅពេលណា ។
- សូម្បីតែអង្គ ព្រះអរហន្ត ត្រូវអស់ព្រះជន្ម ចប់សង្ខារ
បែកធ្លាយបញ្ចក្ខន្ធ គ្រប់អាត្មា តែព្រះអង្គលា មានគោលដៅ ។
- ចំណែករូបយើង បុថុជ្ជន គ្មានដឹងតំបន់ កំណត់ត្រូវ
មានពុទ្ធវចនៈ បំភ្លឺផ្លូវ ដើម្បីចេញទៅ រកត្រើយនាយ ។
- កើតមកជាមនុស្ស សំណាងមាន ត្រ័យរតន៍ជាស្ពាន ឆ្លងអបាយ
ស្ពាននៅជិតទេ កុំអោយឆ្ងាយ ចូរសម្របកាយ កុំភ្លេចភ្លាត់ ។
- ហៃសាធុជន ផងទាំងឡាយ ខ្ញុំសូមឱនកាយ ប្រណិប័តន៍
ខ្ញុំបានបរិយាយ រាយគ្រប់ម៉ាត់ ចេញពីដួងចិត្ត ឥតត្រឡប់។
- បើមានខ្វះបាត់ ភ្លាត់ឆ្គាំឆ្គង សូមមេត្តាផង កុំខ្ចើមស្អប់
ព្រោះមានចេតនា ខ្លាំងលើសលប់ ខំចារបានចប់ តាមលំអាន ។

- អវសានខ្ញុំសូម រំលឹកគុណ អង្គព្រះអរហន្ត ទាំងប៉ុន្មាន
និងព្រះអរិយៈ ថ្លៃថ្កើងថ្កាន សូមអធិដ្ឋាន ដោយគោរព ។
- ពេលនេះរូបខ្ញុំ អ្នកចារចែង រៀបរាប់ថ្លាថ្លែង តែងគម្រប់
រឿងព្រះថេរី ថ្លៃលើសលប់ ត្រូវបានបញ្ចប់ សង្ខេបន័យ ។
- សូមអនុភាព ព្រះពុទ្ធពរ តាមកុសលធម៌ បានជោគជ័យ
សូមឧទ្ទិសដល់ ញាតិគ្រប់វ័យ ប្រកបដោយក្តី សន្តិបរំ ។
- បានអានបានស្តាប់ ចាំក្នុងចិត្ត ជាប់នៅស្មោរស្និត ចាកទុក្ខំ
ជ្រះថ្លាក្នុងចិត្ត ផ្តល់កំលាំង បង្កើតទីតាំង ជាប់កុសល ។
- សូមបានសម្រេច សមប្រាថ្នា ពាក្យថាទុក្ខា កុំឱ្យយល់
និងបានរួចពី ក្តីកង្វល់ បានសម្រេចដល់ ភពត្រើយនាយ ។
- មានព្រះនិព្វាន ជាទិសដៅ សុខអមតៈនៅ មិនបែកធ្លាយ
អ្នកប៉ងប្រាថ្នា ផ្ចិតផ្ចង់កាយ ព្រោះតែនឿយណាយ នឹងវដ្តៈ ។

# ចប់

សូមអនុមោទនា

# «គុណព្រះពុទ្ធសាសនា»

កាព្យពាក្យប្រាំបី

១- គុណពុទ្ធសាសនា មហាធំធេង ខ្ពង់ខ្ពស់ក្រៃលែង ស្មើរសែងសុរិយា
ឱវាទសម្ពុទ្ធ បរិសុទ្ធមេត្តា ព្រះធម៌ករុណា គឺជាឱសថ ។
២- មនុស្សសត្វទាំងអស់ រងគ្រោះអវិជ្ជា បានយល់គ្រប់គ្នា ចាំចារប្រាកដ
បាបបុណ្យគុណទោស សណ្ដោសឱនអត់ ជឿជាក់ប្រាកដ កំណត់រិះគិត ។
៣- ព្រះពុទ្ធសាសនា គឺជាអង្គម្លប់ មនុស្សសត្វឈរឈប់ ក្រោមម្លប់បពិត្រ
ម្លប់សែនត្រជាក់ ដូចទឹកអម្រឹត ក្រេបព្រះធម៌ពិត សុខឥតគណនា ។
៤- ព្រះពុទ្ធសាសនា មាគ៌ាល្អស្អាត ហាមមនុស្សៈជាតិ កុំបៀតបៀនគ្នា
ពៀរត្រូវរម្ងាប់ សម្លាប់អវិជ្ជា មិនចងពៀរគ្នា ឈ្នះមារឫស្យា ។
៥- ទ្រឹស្ដីសម្ពុទ្ធ មុះមុតស្មោះសរ សាងល្អបានល្អ គោលធម៌សាសនា
សាងអាក្រក់បាន អាក្រក់វិញណា រសន៍យខ្លឹមសារ ថ្លៃថ្លាពិសិដ្ឋ ។
៦- ព្រះពុទ្ធសាសនា គ្មានការបន់ស្រន់ មនុស្សខ្លះបច្ចុប្បន្ន និយមចូលចិត្ត
មិនយល់ព្រះធម៌ ដែលល្អសុចរិត ជាធម៌ទស្សពិត ប្រព្រឹត្តក្ដីល្អ ។
៧- ព្រះពុទ្ធសាសនា ករុណាមនុស្សសត្វ ដែលជួបវិបត្តិ ជីវិតក្រៃក្រ
ក្រចេះក្រដឹង ក្រក្ដីស្មោះសរ ក្រឃើញផ្លូវល្អ ក្រធម៌ករុណា ។
៨- ព្រះពុទ្ធសាសនា លោកៈវិទូ ព្រះមរមគ្រូ អង្គសាស្ដាចារ្យ
ឱ្យមានសីលប្រាំ ចងចាំរក្សា ឫសកែវសីលា សិក្ខាបទប្រាំ ។
៩- ឱ្យចេះធ្វើទាន និងមានករុណា នៅលើលោកា គ្មានអកុសលកម្ម
មានសន្តិភាព មិនប្រេះបែកស្រាំ ទាននិងសីលប្រាំ តចាំជាតិមុខ ។
១០- ជួបសម្បត្តិមនុស្ស មានយសទ្រព្យា សម្បត្តិសួគ៌ា ស្អាតថ្លាឆ្ងាយទុក្ខ
សម្បត្តិនិព្វាន បានបរមសុខ ចាកផុតក្ដីទុក្ខ ជួបសុខអមតៈ ។
១១- សាសនាសម្ពុទ្ធ មុះមុតមហិមា ព្រះអភិធម្មា មាគ៌ាសច្ចៈ
អង្គព្រះអរិយ ប្រល័យអសវៈ ឈានដល់អមតៈ គឺព្រះនិព្វាន ។

# « ហេតុការណ៍ថ្ងៃពេញបូណ៌មី »

## " បទបថ្យាវដ្ត "

១- ប្រាំពីរហេតុកាណ៍ មហាទីបលោក មង្គលជ័យជោគ ផ្ទៃលោកអស្ចារ្យ
កាលព្រះពុទ្ធអង្គ បិតគង់ធម្មា កើតមានព្រឹត្តិកាណ៍ ទិវាបូណ៌មី ។

២. ព្រហស្បត្តិ៍ឆ្នាំរកា មហាសួរស្តី អាសាឍ្ហបូណ៌មី រស្មីថ្លៃថ្លា
ព្រះពោធិសត្វ និវត្តន៍ចាកលា តុសិតសួគ៌ា ទិវាចាប់ថ្លៃ ។

៣. ថ្ងៃសុក្រឆ្នាំចរ បវរជោគជ័យ វិសាខបូណ៌មី សិរីឧត្តម
ចាកផ្ទៃមាតា ខ្ជីរខ្ជរឥន្ទព្រហ្ម ចុះមកជួបជុំ បង្គំវន្ទា ។

៤. ចោះអាសាឍ្ហបូណ៌មី ចក្រីលិលា ចេញសាងបុព្វជា ជ្រះថ្លាហឫទ័យ
ប្រាថ្នាត្រាសដឹង ពង្រឹងខន្តី សង្រួមឥន្ទ្រីយ៍ និស្ស័យចេស្តា ។

៥. ពុធវិសាខបូណ៌មី នៃឆ្នាំរការ កក្រើកពសុធា ឈ្នះមារសាមាន្យ
ត្រាស់ដឹងបរិបូណ៌ សម្ពោធិញ្ញាណ ទ្រង់សម្រេចបាន សម្ពុទ្ធលោកា ។

៦. អាសាឍ្ហបូណ៌មី នៃឆ្នាំរកា អង្គព្រះសាស្តា សម្តែងធម្មចក្ក
ប្រោសបញ្ចវគ្គី នូវធម៌សច្ចះ កើតហេតុផ្អើលភ្ញាក់ ញ័រញាក់ពសុធា ។

៧. បូណ៌មីមាឃម្សាញ់ ពោរពេញអនិច្ចា ទ្រង់ដាក់សង្ខារ ថានិងនិព្វាន
នៅក្នុងត្រីមាស វិបល្លាសន៍កើតមាន ទេព្តាគ្រប់ឋាន ស្តាយឥតឧបមា ។

៨. វិសាខបូណ៌មី គឺថ្ងៃអង្គារ អង្គព្រះសាស្តា បរិនិព្វាន
ទីបលោករំជួល ជ្រួលគ្រប់ទេវស្ថាន បរិស័ទគ្រប់ប្រាណ ខ្សឹកខ្សួលអួលអាក់។

➢ **ពោល:** ហេតុទាំងប្រាំពីរ ថ្ងៃពេញបូណ៌មី ថ្ងៃមានជោគជ័យ ដូចក្តីប្រាថ្នា
នៃព្រះសម្ពុទ្ធ ធ្លុះមុតមហាស្ចារ្យ ចាកវដ្តសង្សារ ដល់មហានិព្វាន ។

សៀមរាប ១កើត ខែពិសាខ ឆ្នាំថោះ ព.ស ២៥៥៤ ត្រូវនឹងថ្ងៃទី ០៣ ខែឧសភាព ឆ្នាំ២០១១

# អនិច្ចារូបកាយ

## ( បទ: កាកគតិ )

១- កាយអើយអើយកាយ កាយនិងបែកធ្លាយ រលាយពិតណា
កាយអនិច្ចំ ទុក្ខំអនត្តា កើតហើយមរណា
អនិច្ចាណាស់កាយ ។

២- វិញ្ញាណចេញទៅ ចោលរូបកាយនៅ កូនចៅសោកស្តាយ
កាយរលួយខ្លោច អសោចណាស់កាយ កាយស្រស់ឆោមឆាយ
ប្រែក្លាយសាកសព ។

៣- គ្មានអ្វីសល់នៅ បានជាប់យកទៅ នៅទីបញ្ចប់
មានតែកុសល បុណ្យផលកំណប់ ឬបាបវេចខ្ចប់
កំណប់អកុសល ។

៤- កាលជីវិតរស់ ខំគ្មានថ្ងៃលោះ ស្វែងយសលាភផល
ចិញ្ចឹមកូនចៅ ទុកនៅកេរគល់ បញ្ចប់បានយល់
តទល់មច្ចុ ។

៥- សែនអាណិតខ្លួន កូនខំថែជូន នៅមិនស្រណុក
ម្នាក់ឯងប្តូរផ្តាច់ នឹងស្តេចមច្ចុ កាយអស់ក្តីសុខ
ទុក្ខដល់រលត់ ។

# មរណៈសតិ

វន្ទាមិ ពុទ្ធំ គុណសាគរន្តំ សត្តា សទា ហោន្តុ
សុខី អវេរា កាយោ ជិឃញ្ញោ សក លោ
ទុគន្ធោ គច្ឆន្តិ សព្វេ មរណំ តថាហំ ៕

១- ខ្ញុំសូមថ្វាយបង្គំ ព្រះបរម អង្គសម្ពុទ្ធ
មានគុណលើសព្វសត្វ ដូចសមុទ្រ ធំមហិមា ។
២-សូមសត្វទាំងអស់ ជួបប្រទះ ក្ដីសុខជា
កុំមានពៀរនឹងគ្នា គ្រប់វេលា គ្រប់ៗកាយ ។
៣-កាយយើងទាំងមូលនេះ ក្លិនស្អុយឆ្អេះ អសោច សាយ
រមែងនឹងអន្ដរាយ ស្លាប់បែកធ្លាយ គ្រប់រូបបា ។
៤-គួរឱ្យសង្វេគណាស់ ពុំដឹងច្បាស់ ថាថ្ងៃណា
មច្ចុមកប្រហា ដល់អាត្មា អញនេះអើយ ។

# កាយអនត្តា

(កាព្យប្រាំពីរពាក្យ)

- អនិច្ចារូបកាយ យើងនេះអើយ បានកើតមកហើយ ត្រូវមរណា
ជួបនិងទុក្ខព្រួយ ព្រាត់ប្រាស់គ្នា ពុំមាននរណា គេចវេះ បាន ។
- បានជួបគ្នាហើយ និងបានព្រាត់ យូរហើយនិងឆាប់ គ្មានសុខសាន្ត
វ័យក្មេងរូបកាយ ស្រស់កល្យាណ មិនបានប៉ុន្មាន ត្រូវទ្រោមទ្រុឌ ។
- ហាមចាស់ឈឺស្លាប់ ក៏មិនបាន ទុក្ខព្រួយជាប់ប្រាណ ភ័យគត់ស្លុត
ពេលដែលធាតុបួន ត្រូវរលត់ គេបានសន្មត់ ឈ្មោះថាសព ។
- គេខ្លាចគេខ្ពើម មិនហានជិត ទោះបីញាតិមិត្ត គេបញ្ចប់
គេផ្តាច់ចេតនា ឈប់សេបគប់ ព្រោះវាជាសព ឥតបានការ ។
- ច្បាស់ថារូបយើង រូបមែនពិត តែរូបប្រឌិត ពីកាមា
ល្អតែខាងក្រៅ ក្នុងផ្ដែល្វា ពេលឃើញប្រេះឆា មហាខ្លាចចិត្ត ។
- បើស្អប់រូបនេះ ត្រូវជៀសចេញ បើនៅស្រឡាញ់ ទុក្ខតាបស្អិត
ត្រូវស្វែងសាកសួរ លោកបណ្ឌិត បំភ្លឺធម៌ពិត ព្រះទ្រង់ញាណ ។
- ព្រះធម៌ជាផ្លូវ ប្រសើរបំផុត សីលល្អបរិសុទ្ធ គឺជាស្ពាន
កុសលបុណ្យទាន គឺជាយាន ឆ្លោះសួគ៌និព្វាន សម្រេចហោង ។

---

ថ្ងៃនេះខ្ញុំដើរស្រួល ក្រោយដេកដួលក្លាយជាសព
ត្រូវគេដុត ឬ កប់ ទីបញ្ចប់រលាយសូន្យ ។

# "មាស-ពេជ្រ និង សីល"

(កាព្យពាក្យប្រាំពីរ)

១ មាសពេជ្រចរណៃ ថ្លៃកន្លង
មនុស្សយើងគេផង ប៉ងចង់មាន
រកប្រាក់សន្សំ ទិញអោយបាន
លំអខ្លួនប្រាណ តាមចំណង់ ។

២ អ្នកមានពេជ្រពាក់ គេដឹងថា
អ្នកមានកិត្យា ថ្លៃខ្ពស់ខ្ពង់
ព្រោះអលង្ការថ្លាចែងចាំង
ពាក់តាមចំណង់ គាប់នេត្រា ។

៣ ឈ្មោះពេជ្រទាំគ្រាប់ តម្លៃខ្ពស់
យល់ល្អឥតខ្ចោះ សមកាយា
តែបើអ្នកពាក់ ចិត្តឫស្យា
គ្រាប់ពេជ្រប៉ុនណ្ណា ឥតប្រយោជន៍ ។

៤ ពេជ្រថ្លៃមិនបិទ បាំងម្ចាស់បាន
បើម្ចាស់សាមាន្យ កេរ្តិ៍អសោចន៍
គំនិតរលួយ ឆៅហើយខ្លោច
ទោះពាក់ស្រោបស្រោច ឥតតម្លៃ ។

៥ បើប្រៀបនិងជន រូបអាក្រក់
មានសីលជាប់ដក់ ក្នុងហឫទ័យ
សន្សំកុសល អចិន្ត្រៃយ៍
សីលមានរស្មី ថ្លៃក្រៃលែង ។

៦ សីលធម៌បាំងបាត់ រូបអាក្រក់
សីលក្រអូបដក់ មិនខ្លាចក្រែង
សីលឈ្នះមោហៈ មិនវង្វេង
សីលមិនចំបែង ក្រែងគេប៉ង ។

៧ មាសពេជ្រគេអាច ទិញលក់បាន
សីលទានមិនមាន ទិញលក់ហោង
មាសពេជ្រគេលួច បានតាមប៉ង
ម្ចាស់អ្នកគ្រប់គ្រង ភ័យការពារ ។

៨ មានមាសពេជ្រ ហើយត្រូវមានសីល
កុំអោយមន្ទិល ក្នុងអាត្មា
ព្រោះសីលក៏ជា អលង្ការ
ពាក់ក្នុងចិន្តា ចារនិស្ស័យ ។

៩ មានសីលចាត់ដូច មានទ្រព្យធន
ល្អពីបច្ចុប្បន្ន គ្មានទោសពៃ
ទៅបរលោក ប្រសើរក្រៃ
ជួបព្រះរតនៈត្រៃ គ្រប់ៗជាតិ ។



លី ឡាវុន

អ្នកចូលសទ្ធាបង្កើតសៀវភៅនេះមានរាយនាមដូចខាងក្រោម៖

-លោក ថេង ស៊ាងលី និងអ្នកស្រី លី ស៊ានហ៊ែរ
-លោក ឡៃ ស៊ីថា និងអ្នកស្រី លី ស៊ានឡុត
-លោក ស្រី ប៊ុនធឿន និងអ្នកស្រី លី ឆវី
-លោក លី ប៊ុនហៃ និងអ្នកស្រី អ៊ុន សារ៉ន
-លោក ឡៃ ម៉ានី និងអ្នកស្រី ម៉ៅ ផារ៉ុម
-លោក ឡៃ ប៉ូទី និងអ្នកស្រី សោមសុភាព
-លោក គង់ ម៉េងវី និងអ្នកស្រី ឡៃ ដាវី
-លោក ហ៊ែរ ពិសិដ្ឋ
-លោក ហ៊ែរ ពិចិត្ត និងអ្នកស្រី ជ្រឹង ឆេងលី
-លោក ហ៊ែរ ពិសេស និងអ្នកស្រី ផៀង ស្រស់
-លោក នុត សិទ្ធិសិទ្ធី និងអ្នកស្រី ហ៊ែរ ទងវង
-លោក កង ជាដារិន និងអ្នកស្រី ហ៊ែរ តួចគន់
-លោក អាំង សេងហេង និងអ្នកស្រី ថេង ស៊ានមុំ
-លោក ឈរ វិស្ណុគ្រ និងអ្នកស្រី លី កែវមុនី
-លោក អាំង សេរីចិត្រ និងអ្នកស្រី ឡៃ គឹមពុំ
-លោក ឡឹង លាងគ្រី និងអ្នកស្រី លី ស៊ានទង
-លោក លឹម ស៊ុបហុក និងអ្នកស្រី លី ស៊ានថូ
-លោក ឡៃ លីនណា និងអ្នកស្រី គី ប៊ុនណារី
-លោក អាំង លីនហ៊ីន និងអ្នកស្រី ផេង ស៊ានម៉េង
-លោក ហេង បូរាណ និងអ្នកស្រី គី ណាវឿន
-អ្នកស្រី គី ណារិន -អ្នកស្រី គី ណារី
-លោក សាយ សុផល និងអ្នកស្រី គី ណារី
-លោក សោម សាម៉ុន និងអ្នកស្រី ស៊ូ សុធារី
-ឧបាសិកា គង់ ផេង -ឧបាសិកា អ៊ឹម នាងនួន

# តាំងចេតនាក្នុងធម្មទាន

បុញ្ញកម្ម ជាកុសល ដែលយើងខ្ញុំជ្រះថ្លាសទ្ធា នូវធម្មទាននេះកើតបានជាបុណ្យកុសល កើតមានដល់លោកអ្នកមានគុណដែលចែកឋានក្តី នៅរស់ក្តី ព្រមទាំងយើងខ្ញុំទាំងអស់គ្នា សូមបានរួចផុតចាកទុក្ខទាំងពួង រស់នៅប្រកបដោយសុខសន្តិភាព ។

សូមមាន បញ្ញា សម្មាទិដ្ឋិ ការងាររីកចម្រើនសាយសព្វដល់ទាំងកូនចៅទាំងអស់ ។

បច្ចុប្បន្ន និងអនាគតជាតិ សូមបានជួបនឹងព្រះរតនៈត្រ័យជាទីពឹង ជាទីរឭកគ្រប់ៗជាតិ ។

យើងខ្ញុំជាកូន ខ្មៅ យុនសំរ៉ង ខ្មៅ យ៉ាតណៃ ខ្មៅសុខផល ខ្មៅ វិសាល ខ្មៅ វ៉ាមុន ខ្មៅ ភារាដា ខ្មៅ ចំរើន ខ្មៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្មៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **គឹម វាសនា**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្មៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## រឿង ព្រះនាង យសោធរា ពិម្ពា

ឈ្មោះលោកអ្នកចូលរួមបោះពុម្ពធម្មទានសៀវភៅមានដូចខាងក្រោម៖

| | |
|---|---|
| -ឧកញ៉ា ផៃ ហុកឈួន និងលោកជំទាវ អ៊ឹង ស៊ីស្រ៊ន់ | 200$ ភ.ព |
| -ឯកឧត្តម សុខ ស៊ុនលីន និងលោកជំទាវ ឈឹម ហ៊ាវ | 80$ ស.រ |
| -លោក លឹម ស៊ីបហុក អ្នកស្រី លី ស៊ានថូ ព្រមទាំងកូន | 80$ ស.រ |
| -ឧបាសក រស់ ជ្រឹង ឧបាសិកា សន សម្បត្តិ ព្រមទាំងកូន | 80$ ភ.ព |
| -លោក សួង សន្តិភាព អ្នកស្រី ជួន សុធា | 80$ ភ.ព |
| -វិទ្យុផ្សាយសម្លេងព្រះពុទ្ធសាសនាកម្ពុជរដ្ឋ ខេត្តសៀមរាប | 80$ |
| -ឧបាសិកា ស៊ំរិទ្ធិ ថូ ព្រមទាំងកូន | 25 $ ស.រ |
| -ឧបាសិកា អ៊ីវ ឈីវហ៊ុន ព្រមទាំងកូន | 25 $ ស.រ |
| -អ្នកស្រី ស៊ង ឆេងគន -អ្នកនាង ស៊ុន សុខហ៊ែរ | 25 $ ស.រ |
| -លោក ឡៃ ប៉ូទី អ្នកស្រី សោម សុភាព | 20 $ ស.រ |
| -លោក ស៊ិន សែន អ្នកស្រី ស៊ុន សុគន្ធារដ្ឋ | 20 $ ស.រ |
| -ឧបាសក ឡេង ឃាន ព្រមទាំងកូន | 15 $ ស.រ |
| -លោក ហៀប មី អ្នកស្រី ស៊ង ឆេងហាន ព្រមទាំងកូន | 20 $ ស.រ |
| -លោក សួង សុភា អ្នកស្រី ទាវ សិរីរ័ត្ននា | 20 $ ស.រ |
| -ឧបាសក គាន អ៊ីវ ឧបាសិកា អ៊ាប ស៊ីវគីម | 10 $ ស្ទោង |
| -លោក វ៉ា វណ្ណា អ្នកស្រី ស៊ង ឆេងគី | 10$ ភ.ព |
| -ឧបាសិកា លឹម ឡាយហ៊ាង ព្រមទាំងកូន | 10 $ ស.រ |
| -លោក ម៉ា គឹមហ៊ៅ អ្នកស្រី ស៊ុន សុភាព | 10 $ ស.រ |

លោកអ្នកចង់បោះពុម្ពសៀវភៅនេះជាធម្មទាន
សូមទំនាក់ទំនងតាមលេខទូរស័ព្ទ ដូចខាងក្រោម ៖
(088 55 00 187 - 012 647 644)